CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១២ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងបើកឆ្នេរសមុទ្រឡើងវិញសម្រាប់ការកំសាន្ត

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – ជាការកែប្រែលើបទបញ្ជារក្សាសុវត្ថភាពដោយនៅផ្ទះរបស់ទីក្រុងឡុងប៊ិចទីក្រុងនឹងបើកឆ្នេរសមុទ្រសាធារណៈឡើងវិញទាំងអស់នៅឡុងប៊ិចសម្រាប់សកម្មភាពកម្សាន្តដែលនឹងចាប់ផ្តើមពីថ្ងៃពុធទី ១៣ ខែឧសភានិងបន្តរហូតដល់មានការជូនដំណឹងបន្ថែម។

លោកអភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "ការបើកឆ្នេរសមុទ្ររបស់យើងឡើងវិញគឺជាជំហានមួយឆ្ពោះទៅរកឱកាសកាន់តែច្រើនដើម្បីរីករាយនឹងទីធ្លាចំហរបស់យើង។ ខ្ញុំដឹងថាមនុស្សជាច្រើននៅក្នុងសហគមន៍របស់យើងទន្ទឹងរង់ចាំការកម្សាន្តបន្ថែមទៀតហើយខ្ញុំសូមលើកទឹកចិត្តឱ្យអ្នករាល់គ្នាបន្តរក្សាចម្ងាយរាងកាយពីគ្នាដើម្បីយើងអាចបន្តដំណើរទៅមុខដោយសុវត្ថិភាព។"

ឆ្នេរសមុទ្រនឹងបើកជារៀងរាល់ថ្ងៃចាប់ពីពេលថ្ងៃរះរហូតដល់ថ្ងៃលិចសម្រាប់សមាជិកទោលឬសមាជិកក្នុងគ្រួសារតែមួយដើម្បីប្រើប្រាស់សម្រាប់ការកម្សាន្តរួមមាន៖

- ហែលទឹក
- ជិះកាយ៉ាក់
- ដើរនិងរត់
- ជិះក្តារខ្លែង
- និងសកម្មភាពកំសាន្តស្រដៀងនឹងសកម្មភាពខាងលើ

បន្ទប់ទឹកនៅឆ្នេរសមុទ្របានត្រូវបើកដោយប្រកាន់ខ្ជាប់នូវពិធីការរក្សាចម្ងាយរាងកាយពីគ្នា។ ជាវិធានការបង្ការជាមុនបុគ្គលិកកំពុងធ្វើការសំលាប់មេរោគនៅតាមមូលដ្ឋានជាប្រចាំដើម្បីទប់ស្កាត់ការរាលដាលនៃមេរោគ។

ឆ្នេរសមុទ្ររបស់រ៉ូសីសម្រាប់ឆ្កែ (Rosie's Dog Beach) នឹងបើកឡើងវិញហើយដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នានៅទូទាំងទីក្រុងនិងជាមួយខោនធី Los Angeles នោះឧទ្យានសម្រាប់ឆ្កែរបស់ទីក្រុងនឹងបើកដំណើរការឡើងវិញផងដែរ។

ឆ្នេរនិងឧទ្យានសម្រាប់ឆ្កែក្នុងការកម្សាន្តសកម្មនឹងបើកដោយមានច្បាប់ជាក់លាក់ដែលនៅតែមានសារៈសំខាន់ដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩។

អ្នកដើរកម្សាន្តតាមឆ្នេរខ្សាច់និងអ្នកដែលមកលេងឆ្នេរនិងឧទ្យានសម្រាប់ឆ្កែត្រូវតែ៖

- ស្ថិតនៅចម្ងាយយ៉ាងតិច ៦ ហ្វីតពីអ្នកដទៃគ្រប់ពេល។
    - សមាជិកនៃគ្រួសារតែមួយត្រូវបានលើកលែង។
- ចៀសវាងកន្លែងដែលមានមនុស្សច្រើន។
- ពាក់ម៉ាស់ឬរបាំងមុខនៅពេលនៅជិតអ្នកដែលមិនមែនជាសមាជិកគ្រួសារ។
    - ការពាក់ម៉ាស់មិនតម្រូវនៅពេលហាត់ប្រាណតែម្នាក់ឯងហើយរក្សាចម្ងាយរាងកាយពីអ្នកដទៃ។
- រក្សាចំងាយឆ្ងាយពីរាងកាយអោយបាន ៦ ហ្វីតរឺច្រើនជាងនេះនៅពេលដើរក្បែរអ្នកដទៃ។
- បន្តដំណើរទៅមុខដោយមិនស្ថិតនៅកន្លែងណាមួយយូរលើកលែងតែត្រូវការសម្រាកមួយភ្លែតតែប៉ុណ្ណោះ។
- នៅផ្ទះប្រសិនបើឈឺ។
- លាងសម្អាតដៃលោកអ្នកឱ្យបានញឹកញាប់រួមទាំងមុននិងក្រោយទៅលេងនៅឆ្នេរនិងឧទ្យាន។

ការប្រមូលផ្តុំនៃគ្រប់ទំហំត្រូវបានហាមឃាត់នៅឆ្នេរនិងឧទ្យានទាំងអស់រួមទាំងប៉ុន្តែមិនកំណត់ចំពោះព្រឹត្តិការណ៍ ការប្រកួតនៃអត្តពលកម្ម ជំរុំយុវជន និងកម្មវិធីកម្សាន្ត។ កៅអីអង្គុយ ប៉ារ៉ាំ ធុងទឹកកក ការគេងហាលថ្ងៃ ឬសកម្មភាពដែលនៅមួយកន្លែងស្រដៀងនឹងសកម្មភាពទាំងនេះលើឆ្នេរខ្សាច់ឬក្នុងឧទ្យាននានាត្រូវបានហាមឃាត់។ កន្លែងលេងនៅតែបិទ។

ចំណតរថយន្តនិងផែនឹងនៅតែបិទជាសាធារណៈ។ ប្រជាជនដែលមានលិខិតអនុញ្ញាតចតរថយន្តពិសេសដើម្បីបន្ធូរបន្ថយការកកស្ទះកន្លែងចតនឹងនៅតែអាចប្រើប្រាស់កន្លែងទាំងនោះបាន។

ទីក្រុងបានបិទជាបណ្តោះអាសន្ននូវឆ្នេរសាធារណៈកាលពីខែមីនាដោយអនុលោមតាមបទបញ្ជា "ស្នាក់នៅផ្ទះ" របស់រដ្ឋនិងបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" របស់ទីក្រុងឡុងប៊ិចដើម្បីជួយទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩។

ការបើកឆ្នេរសមុទ្រសម្រាប់ការកម្សាន្តគឺជាសកម្មភាពទី ៣ ដែលត្រូវបានអនុវត្តដោយទីក្រុងចាប់តាំងពីឡុងប៊ិចបានចូលដំណាក់កាលទី ២ នៃផែនការបួនដំណាក់កាលរបស់អភិបាលរដ្ឋ Gavin Newsom ដើម្បីកាត់បន្ថយការដាក់កម្រិតជាបណ្តើរៗ។ វិធានការណ៍ផ្សេងទៀតរួមមានការបើកឡើងវិញនៃហាងលក់រាយសម្រាប់ការមកយករបស់នៅតាមចិញ្ចើមថ្នល់នៅថ្ងៃសុក្រទី ៨ ខែឧសភានិងការបើកឡើងវិញនៃផ្លូវនៃឆ្នេរសមុទ្រ ផ្លូវជិះកង់ ផ្លូវលំនិងទីលានលេងតិនីសនៅថ្ងៃច័ន្ទទី ១១ ខែឧសភា។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាមអំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###